កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ( ASPIRE )

# បច្ចេកទេសការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ
# ធន់ទៅ នឹងការប្រែប្រួលអាកាសធាតុ





**រៀបចំដោយ :** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃ អគ្គនាយកដ្ឋានកសិកម្ម

**ឧបត្ថម្ភដោយ:** កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE)

**ភ្នំពេញ ខែ វិច្ឆិកា ឆ្នាំ ២០១៦**

# មាតិកា

ទំព័រ

មាតិកា........................................................................................ 1
សេចក្តីថ្លែងអំណរគុណ........................................................................................ 1
មេរៀនទី ១: ពូជ........................................................................................ 2
មេរៀនទី ២: លក្ខណ:ទូទៅក្នុងការសាងសង់ទ្រុង........................................................................................ 6
មេរៀនទី ៣: វិធីសាស្រ្តចិញ្ចឹមកូនមាន់កំឡុងពេលបម្រែបម្រួលអាកាសធាតុ........................................................................................ 11
មេរៀនទី ៤: អនាម័យ និង វិធានការណ៍ការពារជម្ងឺ........................................................................................ 23
មេរៀនទី ៥: ជម្ងឺ និង ការចាក់ថ្នាំការពារ........................................................................................ 27
១. ជម្ងឺអាសន្នរោគ........................................................................................ 27
២. ជម្ងឺញូវកាស ឬ ជម្ងឺដង្កោរ........................................................................................ 28
៣. ជម្ងឺអុតបក្សី........................................................................................ 29
៤. ជម្ងឺផ្តាសាយបក្សី........................................................................................ 30
មេរៀនទី ៦: ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូច ផ្នែកការចិញ្ចឹមមាន់........................................................................................ 31
ឯកសារយោង........................................................................................ 37

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់ជំនួយ មូលនិធិអភិវឌ្ឍន៍កសិកម្មអន្តរជាតិ (IFAD) ដែលបានផ្តល់កម្ចីដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការអនុវត្ត កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (ASPIRE) មានគោលបំណង កាត់បន្ថយភាពក្រីក្រ និងបង្កើនភាពធន់ របស់គ្រួសារ កសិករក្រីក្រ និងអ្នកងាយរងគ្រោះកសិករខ្នាតតូចនៅកម្ពុជា។ កម្មវិធីបានផ្តល់ថវិកា ដល់អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ក្នុងការអនុវត្ត សមាសភាពទី២ នៃកម្មវិធីគឺអភិវឌ្ឍសមត្ថភាពសេវាផ្សព្វផ្សាយកសិកម្ម ដើម្បីជួយគាំទ្រការកែលម្អសេវាផ្សព្វផ្សាយកសិកម្ម នៅថ្នាក់ក្រោមជាតិ និងមូលដ្ឋាន តាមរយៈបង្កើនគុណភាពផ្សព្វផ្សាយកសិកម្ម និងគ្រប់គ្រងចំណេះដឹង និងពង្រឹងធនធានមនុស្សសម្រាប់ ផ្សព្វផ្សាយកសិកម្ម។

បម្រែបម្រួលអាកាសធាតុ មានការប្រែប្រួលខ្លាំង រដូវដែលប្លាស់ប្តូរ បង្កឲ្យមានផលប៉ះពាល់ដល់ជីវភាព រស់នៅរបស់កសិករ និងផលប៉ះពាល់ដល់របរកសិកម្ម ទទួលប្រាក់ចំណូលទាបដូច្នេះហើយទើបកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ រៀបចំឯកសារផ្តល់ចំណេះដឹងនេះឡើងដើម្បីឆ្លើយតបនឹង បម្រែបម្រួលអាកាសធាតុ ឲ្យបានទាន់ពេលវេលា ដែលជាតម្រូវការរបស់កសិករខ្នាតតូចគ្រប់ៗគ្នា ទាំងក្នុងនឹងក្រៅគម្រោងផងដែរ ។

យើងសង្ឃឹមថាឯកសារនេះ និងជួយដល់ មន្ត្រីផ្សព្វផ្សាយ ភ្នាក់ងារផ្សព្វផ្សាយ បង្ហាត់ពីបច្ចេកទេសការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារដែលឆ្លើយតបទៅ នឹងការប្រែប្រួលអាកាសធាតុ វាជាវិធីសាស្រ្តងាយៗ សាមញ្ញក្នុងការចិញ្ចឹមសត្វ ដែលកសិករអាចធ្វើបាន និងទទួលប្រាក់ចំណូលកើនឡើង ។

ឯកសារណែនាំ "**ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ**" នេះជា សមិទ្ធិផលថ្មីមួយរបស់កម្មវិធី ASPIRE ភាពជោគជ័យក្នុងដំណើរការរៀបចំសៀវភៅនេះ គឺអាស្រ័យទាំងស្រុងលើកិច្ចសហប្រតិបត្តិការ និងការចូលរួមក្រុមការងារបច្ចេកទេស របស់កម្មវិធីនៃ អគ្គនាយកដ្ឋានកសិកម្ម/នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# មេរៀនទី ១: ពូជ

## ១.គោលបំណង

- ឲ្យកសិករចេះជ្រើសរើសពូជមាន់យកមកចិញ្ចឹមឲ្យធន់នឹងអាកាសធាតុប្រែប្រួលតាមតំបន់
- មាន់មានសុខភាពល្អ ធំធាត់លឿន ត្រូវតាមតម្រូវការទីផ្សារ

## ២.ពូជមាន់នាំចូលពីបរទេស

ផ្តល់ទិន្នផលខ្ពស់ ការចិញ្ចឹមត្រូវអនុវត្តតាមបច្ចេកទេស

### ❖ ពូជមាន់ផ្តល់សាច់

- ពូជអារីយង់







### ❖ ពូជមាន់ផ្តល់ពង

- ពូជអ៊ីសាប្រូន
- ពូជលីហ្គន
- ពូជព្លីមុត



## ៣.ពូជមាន់ក្នុងស្រុក

ពូជនេះធន់អាកាសធាតុមិនសូវរើសចំណីងាយស្រួលចិញ្ចឹម។



មាន់សំពៅ



មាន់ស្ទួយ



មាន់កណ្ដូង



មាន់ថៃ



មាន់គក

## ៤.ពូជមាន់បីសាសន៍(មាន់កូនកាត់)





បានពីការបង្កាត់មេបា ពូជសុទ្ធបរទេសនិង ពូជសុទ្ធបរទេស និងពូជមាន់ ក្នុងស្រុក។ មាន់បីសាសន៍ ចិញ្ចឹមឆាប់ធំ មាឌធំ ធន់ជំងឺ ស៊ីចំណី ក្នុងស្រុក។

## ៥.គុណសម្បត្តិ និងគុណវិបត្តិរបស់ពូជមាន់

| ប្រភេទមាន់ | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| **មាន់ក្នុងស្រុក** | - ធន់ និង អាកាសធាតុប្រែប្រួលក្នុងតំបន់<br>- ស្រួលចិញ្ចឹមមិនរើសចំណី<br>- ចេះក្រាបពង ពូកែថែរក្សាកូន<br>- ចំណាយដើមទុនតិច លក់បានតម្លៃខ្ពស់ | - មាន់មាឌតូច រយៈពេលចិញ្ចឹមយូរ<br>- ការលូតលាស់យឺត ផ្តល់ពងតិច |
| **មាន់នាំចូល** | - មានមាឌធំ ការលូតលាស់លឿន<br>- រយៈពេលចិញ្ចឹមខ្លី ផ្តល់ពងច្រើន | - មិនសូវធន់ និងអាកាសធាតុប្រែប្រួលក្នុងតំបន់<br>- ពិបាកចិញ្ចឹមរើសចំណី មិនចេះក្រាបពង និងបណ្តើរកូន<br>- ទាមទារការថែទាំខ្ពស់ លក់បានតម្លៃទាប |

## ៦.លក្ខណៈទូទៅក្នុងការជ្រើសរើសពូជ

### ❖ ការជ្រើសរើសបា

- មាឌធំសង្ហា ពេញវ័យជំទង់ ចាប់ពី ៥ ដល់ ៧ខែ
- សុខភាពល្អ ទំងន់ពី ២ដល់៣គីឡូឡើង
- ចរិកស្លូតបូត
- ពូកែជាន់មេ
- ប្រវត្តិមេ បាល្អ
- មិនជាន់ឈាម
- មិនមានជម្ងឺតំណពូជ

### ❖ ការជ្រើសរើសមេ

- ធំមាំរាងសម
- ចន្លោះឆ្អឹងទ្រូងមកគូទមានទំហំបីធ្នាប់ដៃ (ពោះ)
- សុខភាពល្អ  ប្រវត្តិមេ បាល្អ
- ចរិកស្លូតបូត ពូជសាយ កូនពូកែថៃទាំកូន
- មិនជាន់ឈាម  និងមិនមានជម្ងឺតំណពូជ









# មេរៀនទី ២: លក្ខណៈទូទៅក្នុងការសាងសង់ទ្រុង

## ១.គោលបំណង

ក្រោយវគ្គបណ្តុះបណ្តាលសិក្ខាកាម និងចេះពីបច្ចេកទេស៖

- ❖ ការសាងសង់ទ្រុង មេមាន់យកពង មាន់យកសាច់ កូនមាន់ ទ្រុងមាន់ជីវសុវត្ថិភាព ដើម្បីការពារ ជម្ងឺនិងទប់ទល់កំណើនសីតុណ្ហភាព

## ២. ការសាងសង់ទ្រុង

- ជួយឲ្យមាន់មានសុខភាពល្អ ការពារកំដៅថ្ងៃ ភ្លៀងខ្យល់

## ៣. គុណសម្បត្តិនៃការសាងសង់ទ្រុងមាន់

- បង្កាត់ និងរក្សាពូជបានល្អ ផ្តល់ទឹក និងចំណី ការគ្រប់គ្រងស៊ុត
- ចាក់ថ្នាំការពារ ការព្យាបាល ការទំលាក់ព្រូន ត្រួតពិនិត្យសុខភាពមាន់បានគ្រប់ពេល កាត់បន្ថយនូវជម្ងឺ
- ប្រមូលលាមកធ្វើជី កាត់បន្ថយការបាត់បង់ ចោរលួច ឬ សត្វសាហាវស៊ី
- បានគិតលើហានិភ័យពេលមានបម្រែបម្រួលអាកាសធាតុផងដែរ។

## ៤. ការជ្រើសរើសទីតាំងសង់ទ្រុង

- មានខ្យល់អាកាសចេញចូលល្អ ទាំងរដូវប្រាំង និងរដូវវស្សា
- ដីទួលមិនជាំទឹក និងមានដង្ហើមទឹករាក់(ដីមានសំណើមទឹក)
- ក្រលាផ្ទៃទ្រុងសង់តម្រូវតាមចំនួនមាន់

- មានប្រភពទឹកស្អាត
- ឆ្ងាយពីទីប្រជុំជន ឆ្ងាយពីផ្ទះបន្តិច មានពន្លឺព្រះអាទិត្យជះចូលពេលព្រឹក និងល្ងាច
- មានរណ្តៅជីកំប៉ុស្ត ចំងាយ៣ទៅ៤ម៉ែត្រពីទ្រុង
- ស្នូកចំណី និងស្នូកទឹក ងាយលាងសំអាត
- ជុំវិញជញ្ជាំងទ្រុង មានសំណាញ់ការពារមូស សត្វល្អិតចង្រៃទិចឬខាំមាន់
- កម្រាលផ្ទៃទ្រុងប្រើអង្កាម អាចមន៍រណាឈើ ដីខ្សាច់ ឬធ្វើជាទ្រនើសម្រាប់មាន់ដេក
- ដំបូលមាន សំយាបវែង ប្រក់ស្បូវ ស្លឹកត្នោត ស្លឹកដូង
- រដូវវស្សា ទ្រុងត្រូវការពារខ្យល់បោកបក់ខ្លាំង ជះភ្លៀងចូល និងធ្វើឲ្យ មានកំដៅក្នុងទ្រុង (ដូចជាដុតធ្យូងក្នុងក្អម ឬង្គ្រាន ឬអំពូលភ្លើងអគ្គីសនី)
- រដូវប្រាំង ក្នុងទ្រុងត្រូវត្រជាក់ ដាំដើមឈើហូបផ្លែ ឬដើមចេក ននោង ក្បែរៗទ្រុងផ្តល់ជាម្លប់ ដាំស្មៅខៀវខ្ចីព័ទ្ធជុំវិញទ្រុង ជួយកាត់បន្ថយកំដៅជះចូលទ្រុង ត្រូវបាញ់ទឹកលើដំបូល ជុំវិញទ្រុងម៉ោង៩ព្រឹក និងម៉ោង២រសៀល បាញ់ទឹកឲ្យជោគជាំ ទើបមានធាតុត្រជាក់ជះចូលក្នុងទ្រុង។

## ៥.ទ្រុងមាន់សាច់

- ត្រូវមានកម្រាលជាប់ដីប្រើអង្កាម អាចរណាសម្រាប់រដូវវស្សា
- រដូវប្រាំងកម្រាលដីខ្សាច់ ទ្រនើសម្រាប់មាន់ដេកពេលយប់ វិធីនេះចិញ្ចឹមមិនព្រលែងចេញក្រៅទ្រុងទេ
- ផ្ទៃទ្រុង១ម៉ែត្រការ៉េ ដាក់មាន់បាន៖
  - ១៥ទៅ២០ក្បាល ក្នុងអាយុ ២ ទៅ ៣ខែ
  - ៨ទៅ១០ក្បាល ក្នុងអាយុ ៣ ទៅ ៤ខែ
  - ៤ទៅ៥ក្បាល ក្នុងអាយុ ៤ ទៅ ៥ខែ





ទ្រុងមាន់សាច់

# ៦. ទ្រុងកូនមាន់

ងាយស្រួលលើកចុះឡើងយកកូនមាន់ដាក់កំដៅថ្ងៃពេលព្រឹកព្រលឹម។

- កំពស់ ៩តឹក មានជើង៤តឹក
- ទទឹង៨តឹក
- បណ្តោយ១ម៉ែត្រ៤តឹក
- យើងត្រូវខ័ណ្ឌចែកជាពីរទ្រុងនិងមានទ្វា គម្របពីលើទាំងពីរទ្រុង











ទ្រុងកូនមាន់

## ៧. ទ្រុងមេមាន់ពង

ទ្រុងមេពងនៅជាប់នឹងទ្រុងមាន់សាច់ ដោយតជាប់ជញ្ជាំងទ្រុងមាន់សាច់មួយចំហៀងនិង បន្ថែមយ៉ាបដំបូលបន្តិចជាការស្រេច៖

- ទទឹង១ម៉ែត្រកន្លះ
- បណ្ដោយតាមប្រវែងទ្រុងមាន់សាច់
- ដាក់សំបុកឲ្យមាន់ពងមានកំពស់ពីដី៧តឹក ឬ កំពស់៩តឹក
- ដាក់ជណ្ដើរ៣ទៅ៤កាំឲ្យមេឡើងពង សំបុកនីមួយៗត្រូវខុសប្លែកគ្នា ។








ទ្រុងមេមាន់ និងមាន់សាច់

## ៨. ទ្រុងមាន់ជីវសុវត្ថិភាព

- ការពារមាន់កុំឲ្យឆ្លងជម្ងឺមកពីខាងក្រៅ ឬពីក្នុងទៅក្រៅ ។ ព័ទ្ធសំណាញ់ ព្រួល ធាងត្នោត ធាងដូង កូនឈើក្រញឹប ដាំដើមកន្ទុំថេត ល្ហុងខ្វង ម្រុំ អង្គាដី អង្កាញ់ ដើមបណ្ដូលពេច និងស្លឹកគ្រៃ។ល។ ក្នុងទីធ្លា ដាំឈើហូបផ្លែៈ ដូង ចេក ស្វាយ ល្ហុង ការពារកុំឲ្យមាន់ចេញក្រៅ និងជាម្លប់ ។
- ដាំស្មៅនៅជុំវិញទ្រុង ដើម្បីជួយឲ្យដីមានសំណើម ជួយកាត់បន្ថយការបំភាយឧស្ម័នកាបូនិក ចេញពីដី និងជួយឲ្យដីរក្សាសីតុណ្ហភាពមិនឲ្យកើឡើងខ្លាំង ជាពិសេសនៅរដូវប្រាំង
- ទ្រុងមាន់ដេក និងទីធ្លា ទទឹង១៥xបណ្ដោយ៣០ម មានដើមឈើហូបផ្លែ សម្រាប់មាន់ជ្រកក្នុងបរិវេណសំណាញ់
- ក្នុងទីធ្លា អាចដាក់ទឹកចំនួន ៣ទៅ ៤កន្លែងសម្រាប់មាន់ផឹក និងជីករណ្ដៅមួយដាក់សម្រាម ឬអាចមន៍មាន់សម្រាប់ទុកធ្វើជាជី សម្រាប់ដាំដំណាំ
- ទំហំទ្រុង ១ម៉ែត្រការ៉េ អាចដាក់មាន់ចិញ្ចឹម ពី ៥ទៅ១០ក្បាល។













ទ្រុងមាន់ជីវសុវត្ថិភាព

# មេរៀនទី ៣: វិធីសាស្ត្រចិញ្ចឹមកូនមាន់កំឡុងពេលប្រែប្រួលអាកាសធាតុ

## ១.គោលបំណង

ក្រោយវគ្គបណ្តុះបណ្តាលសិក្ខាកាម និងបានយល់ដឹងពីៈ

- បច្ចេកទេសចិញ្ចឹម ការផ្តល់ចំណី ទឹក ការចាក់ថ្នាំការពារ និងការថែទាំកូនមាន់ ធន់នឹងអាកាសធាតុប្រែប្រួល

## ២. ការចិញ្ចឹមកូនមាន់

- **ការថែទាំកូនមាន់ទើបញាស់**
  - ត្រូវដាក់កូនមាន់ចូលក្នុងទ្រុងកំដៅ
  - ត្រូវផ្តល់កំដៅឲ្យកូនមាន់ ឲ្យបានត្រឹមត្រូវ
- **ការផ្តល់កំដៅឲ្យកូនមាន់** ករណីការចិញ្ចឹមគ្មានមេ ត្រូវផ្តល់កំដៅឲ្យកូនមាន់ដូចមេដែរ
  - បើសីតុណ្ណភាពទាបកូនមាន់នឹង ខ្សោយ រងា ឈឺ បណ្តាលឲ្យលូតលាស់យឺត
  - បើសីតុណ្ណភាពក្តៅខ្លាំងនឹងធ្វើឲ្យរោមកូនមាន់ដុះមិនល្អ ខ្សោយ ឈឺ ក្រិនមិនធំ

**តារាងសីតុណ្ហភាព (កំដៅ) សម្រាប់កូនមាន់**

| អាយុកូនមាន់ (សប្តាហ៍) | តម្រូវការកំដៅ |
|---|---|
| ០ -១ | ៣៥ -៣២ អង្សាសេ |
| ១- ២ | ៣២- ២៩ អង្សាសេ |
| ២ -៣ | ២៩ -២៦ អង្សាសេ |
| ៣- ៤ | ២៦- ២៣ អង្សាសេ |
| ៤ -៥ | ២៣ -២០ អង្សាសេ |

## ❖ សញ្ញាណបង្ហាញពីកំដៅក្នុងទ្រុងកូនមាន់

- **កំដៅល្មមគ្រប់គ្រាន់:** កូនមាន់ដើររកស៊ីរាយប៉ាយល្អពេញក្នុងទ្រុង
- **កំដៅខ្លាំងជ្រុល :** កូនមាន់ឃ្លាតឆ្ងាយពីប្រភពកំដៅ ឬស្រែកយំពេញទ្រុង ឬរត់ប្រសេចប្រសាច
- **កំដៅត្រជាក់ខ្លាំង:** កូនមាន់ប្រមូលផ្តុំគ្នា ឬ គរលើគ្នា





ការដាក់កូនមាន់ក្នុងទ្រុងកូនមាន់



ទូកំដៅកូនមាន់ប្រើចង្កៀងប្រេងកាត



ផ្តល់កំដៅកូនមាន់ ដោយប្រើរងើកធ្យូង





កំដៅល្មមកូនមាន់ដើររកស៊ីធម្មតា



កំដៅត្រជាក់ខ្លាំងកូនមាន់ដេកគរលើគ្នា



កំដៅខ្លាំងជ្រុលកូនមាន់រត់ចេញពីប្រភពកំដៅ

## ៣. ការផ្តល់ចំណី និងទឹក

ត្រូវគិតពីរដូវកាលអាកាសធាតុប្រែប្រួល កសិករព្យាយាមដាំដំណាំបន្លែ ចិញ្ចឹមជន្លេនជួយសម្រួលដល់ការចំណាយថវិកាសម្រាប់ទិញ ចំណី និងយកមកផ្សំជាចំណីធម្មជាតិវាងាយស្រួលកែតម្រូវតាមអាកាសធាតុប្រែប្រួល។

មាន់ត្រូវមានចំណីអាហារមាន៖ ជាតិសាច់ ជាតិស្ករ ជាតិរ៉ែ ជាតិវិតាមីន នឹងជាតិទឹក ដើម្បីការលូតលាស់ ធំធាត់និងសុខភាពល្អ របស់វា។

| ប្រភេទ | មាននៅក្នុង | អត្ថប្រយោជន៍ |
|---|---|---|
| **១.ចំណីផ្តល់ជាតិសាច់** | សាច់ កាកសណ្តែកសៀង កូនបង្គារ    | បង្កើតកោសិកាសរីរាង្គផ្សេងៗក្នុងខ្លួនសត្វ(សាច់ដុំ ស្បែក ឈាម រោម ក្រចក គំរ) |
| | កូនត្រី សាច់មាន់ កាកដូង    | |
| **២.ចំណីផ្តល់ជាតិស្ករ** (**ថាមពល**) | សណ្តែកសៀង កាកសំណល់ផ្ទះបាយ កាកបាយស្រា    | ផ្តល់ថាមពលសម្រាប់បង្កើនកំលាំង និងការលូតលាស់របស់សត្វ |

| | | |
|---|---|---|
| | ចុងអង្ករ កន្ទក់ម៉ត់ ពោត    | |
| **៣.ចំណីផ្តល់ជាតិរ៉ែ** | សំបកខ្យង អំបិល    | បង្កើនការលូតលាស់របស់ឆ្អឹង និង ឲ្យឆ្អឹងសត្វរឹងមាំ |
| **៤.ចំណីផ្តល់វីតាមីន** | ស្លឹកកន្ទំថេត ត្រកួន    | សម្រាប់ការធំធាត់ ការបន្តពូជ និងសុខភាពល្អ |
| **៥. ទឹក** | ទឹកស្អាត   | បញ្ជូនសារជាតិចិញ្ចឹម ក្នុងសារពាង្គកាយសត្វ ដឹកជញ្ជូនជាតិពុល ចេញទៅក្រៅសរីរាង្គ រក្សាកំដៅ ក្នុងខ្លួនសត្វ ធ្វើឲ្យដងខ្លួនសត្វធំធាត់ល្អ |

## ក. ការផ្សំចំណីដែលមានក្នុងស្រុក

- កំទេចពោត ជាប្រភពសំខាន់នៃប្រូតេអ៊ីន និងសារធាតុធ្វើឲ្យមាន់មានស្បែក និងជើងពណ៌លឿង

**ការផ្សំចំណីសម្រាប់កូនមាន់អាយុ ១ថ្ងៃ ដល់អាយុ ៤៥ថ្ងៃ**

| វត្ថុធាតុដើម | អាយុមាន់ | | |
|---|---|---|---|
| | ១ថ្ងៃ-១៥ថ្ងៃ | ១៥-៤៥ថ្ងៃ | ៤៥ថ្ងៃឡើង |
|  ចុងអង្ករ | ១,៥ គក្រ | ១គក្រ | ១ គក្រ |
|  កន្ទក់ម៉ដ្ឋ | ១,៥ គក្រ | ១,៥ គក្រ | ១,៥ គក្រ |
| ត្រីហាល ឬ កូនត្រីតូច ឬ សណ្តែកសៀង    | ១ គក្រ | ០,៥គក្រ | ០,៤ គក្រ |
| ត្រកួន ឬ ស្លឹកជំឡូងមី ឬ ស្លឹកម្រុំ ឬ ស្លឹកកន្ទំថេត     | ១ គក្រ | ១គក្រ | ២គក្រ |
| អំបិល  ឬ ម្សៅប្រេម៉ិច  | ០,២៥ គក្រ | ០,២៥គក្រ | ០,២៥គក្រ |
| សរុប | ៥,២៥ គក្រ | ៤,២៥គក្រ | ៥,១៥គក្រ |

## បរិមាណចំណីត្រូវផ្តល់ឲ្យកូនមាន់

| អាយុ កូនមាន់ | ចំនួនកូនមាន់ | បរិមាណចំណីផ្តល់ | |
|---|---|---|---|
| | | ទំងន់ចំណី | ចំនួនដងឲ្យស៊ី |
| ១-២១ ថ្ងៃ | ១០ ក្បាល | ១ខាំ (១០០ក្រាម) | ៣-៤ ដងក្នុង១ថ្ងៃ |
| ២១-៤៥ ថ្ងៃ | ១០ ក្បាល | ៦ខាំ (៦០០ក្រាម) | ៣-៤ ដងក្នុង១ថ្ងៃ |
| ៤៥ ថ្ងៃឡើងទៅ | ១០ ក្បាល | ១គីឡូក្រាម | ៣ ដងក្នុង១ថ្ងៃ |

## តម្រូវការទឹកសម្រាប់កូនមាន់ក្នុងមួយថ្ងៃ

| ចំនួនកូនមាន់ | អាយុកូនមាន់ | ចំនួនទឹកក្នុងមួយថ្ងៃ |
|---|---|---|
| ១ ក្បាល | ១ សប្តាហ៍ | 0,0៤ លីត្រ |
| ១ ក្បាល | ២ សប្តាហ៍ | 0,0៥ លីត្រ |
| ១ក្បាល | ៣ សប្តាហ៍ | 0,0៦ លីត្រ |
| ១ ក្បាល | ៤ សប្តាហ៍ | 0,១ លីត្រ |

- ផ្តល់ទឹកស្អាត គ្រប់គ្រាន់ជាប្រចាំ ដើម្បីការលូតលាស់និងផលិតពង
- មាន់ស្លាប់ប្រសិនបើគ្មាន ទឹកផឹក ២៤ ម៉ោង
- មាន់ត្រូវការទឹកច្រើន ដើម្បីខ្លួនវាត្រជាក់ពេលអាកាសធាតុក្តៅ
- តម្រូវការទឹក អាស្រ័យសីតុណ្ហភាពខាងក្រៅ អាយុមាន់ ទម្ងន់ ប្រភេទចំណី និងការផលិតពង
- មាន់ក្នុងស្រុក ប្រើរុក្ខជាតិ ជាថ្នាំជំនួយសុខភាពបន្ថែម៖
    - សំបកស្តៅ សំបកគរ វល្លិ៍ពេជ្រ គល់ស្លឹកគ្រៃ ត្រាំជាមួយទឹក ឲ្យមាន់ផឹករាល់ថ្ងៃនៅរដូវក្តៅ
    - ត្រាំស្រូវ ជាមួយទឹក សំបកស្តៅ ឬ វល្លិ៍ពេជ្រ បាចឲ្យមាន់ស៊ី
    - ស្លាខ្ចី គ្រាប់កន្ទំថេត គ្រាប់សង្កែ ទម្លាក់ព្រូនមាន់
    - ស្លឹកគ្រៃក្រៀម ស្លឹកស្តៅ ថ្នាំជក់ ដាក់ក្នុងសំបុកមាន់កំចាត់ស្រមើល
    - ទម្លាប់ឲ្យមាន់ផឹកទឹកក្នុងស្នូកទឹក(ប្រដាប់ដាក់ទឹក)

# ការធ្វើមេថ្នាំធម្មជាតិ

| វត្ថុធាតុដើម (គ្រឿងផ្សំ) | ទំងន់ | វិធីធ្វើ | វិធីប្រើ |
|---|---|---|---|
| ពន្លៃ  | 0,៥ គីឡូក្រាម | - ចិញ្ច្រាំគ្រឿងផ្សំឲ្យល្អិត<br>- ច្របល់លាយជាមួយស្ករ<br>- ច្រកចូលពីដុង បិទគម្រប<br>- រក្សាទុក១៥ថ្ងៃក្រោយទើបប្រើប្រាស់<br>- បើកគម្របបញ្ចេញខ្យល់១ថ្ងៃម្តងៗ | - យកទឹកមានក្លិនឆ្ងុយ ចំនួន ១ឬ២ស្លាបព្រាកាហ្វេ មកលាយ ចំណី១គីឡូក្រាម ឬលាយជាមួយ ទឹក១លីត្រ |
| ខ្ញី  | ១ គីឡូក្រាម | | |
| រំដេង  | ១ គីឡូក្រាម | | |
| ខ្ទឹមស  | 0,៥ គីឡូក្រាម | | |
| ស្ករត្នោត  | ១ គីឡូក្រាម | | |
| ពីដុងជ័រ ចំណុះ៥គីឡូ  | ១ ពីដុង | | |

## ខ. អំពីស្នូកទឹក ស្នូកចំណី



ស្នូកទឹក និងស្នូកចំណី



ការផ្តល់ចំណី និងទឹកដល់កូនមាន់

- អាកាសធាតុក្តៅ ផ្តល់បន្លែស្រស់ឲ្យមាន់ស៊ីបានច្រើនកាត់បន្ថយ ចំណីមានជាតិស្កបន្តិច បាញ់ទឹកលើដំបូល ជុំវិញទ្រុងម៉ោង៩ព្រឹក និងម៉ោង ២រសៀល បាញ់ទឹកឲ្យជោគជាំ ទើបមានធាតុ ត្រជាក់ជះចូលទ្រុង
- អាកាសធាតុត្រជាក់ពេកត្រូវដាក់កំដៅ (ដូចជាដុតធ្យូងក្នុងក្អម ឬង្គ្រាន ឬអំពូលភ្លើងអគ្គីសនី) បិទបាំងជុំវិញទ្រុងនិងបន្ថែមចំណីមានជាតិស្ក ដាក់មេថ្នាំធម្មជាតិជួយបង្កើនកំដៅក្នុងខ្លួនមាន់ទប់ទល់ជម្ងឺ។

**ការស៊ីចំណី និងផឹកទឹករបស់មាន់ពូជក្នុងស្រុក ចិញ្ចឹមដាក់ទ្រុង**

| អាយុ (សប្តាហ៍) | ការស៊ីចំណី(គ.ក្រ សម្រាប់មាន់ ១០ក្បាល ក្នុងមួយថ្ងៃ) | ការផឹកទឹក (សម្រាប់មាន់ ១០ ក្បាលក្នុងមួយថ្ងៃ(លីត្រ) |
|---|---|---|
| ១-៥ | ០,១៥-០,៣ | ០,២-២ |
| ៦-១០ | ០,៤-០,៦ | ១,១-១,៩ |
| ១១-១៦ | ០,៧-០,៧៥ | ២,៣-២,៥ |
| ១៧-២១ | ០,៨ | ២,៧ |
| ២២-២៤ | ០,៨-១ | ២,៨-៣ |

## ខ. ការធ្វើអនាម័យ និងថែទាំ

- ស្តុកទឹក ចំណីឧស្សាហលាងសំអាត ១ថ្ងៃម្តង
- រំងាប់មេរោគទ្រុងចិញ្ចឹមកូនមាន់បានល្អ មុនដាក់កូនមាន់ថ្មីចិញ្ចឹម
- ប្រើថ្នាំរំងាប់មេរោគ វីមីចអ៊ីយ៉ូឌីន (Vime-Iodine) បាញ់លើផ្ទៃទ្រុងក្នុង និងក្រៅ កំរាល ដី
- ផ្តល់ចំណីអាហារ និងទឹកឲ្យបានគ្រប់គ្រាន់
- មាន់មានជម្ងឺ បំបែកចេញពីមាន់មិនមានជម្ងឺ



ការអនាម័យលើផ្ទៃទ្រុង និងជុំវិញទ្រុង

## គ. ការចាក់វ៉ាក់សាំងការពារជម្ងឺ




វ៉ាក់សាំងអាសន្នរោគ




វ៉ាក់សាំងញូវកាសសែហ្វ បូកអ៊ឹម២៥ក្បាល




វ៉ាក់សាំង ញូវកាសសែហ្វ១០០ក្បាល




វ៉ាក់សាំង ញូវកាសអ៊ឹម១០០ក្បាល




វ៉ាក់សាំងអុតបក្សី

# កម្មវិធីចាក់វ៉ាក់សាំងការពារជម្ងឺកូនមាន់

| អាយុមាន់ | ឈ្មោះជម្ងឺ | ឈ្មោះវ៉ាក់សាំង (ផលិតនៅវៀតណាម) | កម្រិតវ៉ាក់សាំង | ផ្លូវបញ្ចូល | រំលឹកវិញ |
|---|---|---|---|---|---|
| ១-៣ ថ្ងៃ | ញ៉ូវកាស | ញ៉ូវកាស (I2)       | ១ ទៅ<br>២ ដំណក់ | បន្តក់ភ្នែក <br>បន្តក់ក្នុងមាត់  | ក្រោយ៦ខែ |
| ៧-១០ ថ្ងៃ | អុតមាន់ | អុត   | ជួសម្ជុលមុខ២<br>ជួស១ម្ជុល | ជួសផ្ទាំងស្លាប  | |

| | | | | | |
|---|---|---|---|---|---|
| ២ ខែ | អាសន្នរោគ | កុលឡឺរ៉ា   | ១ សេ សេ | ចាក់សាច់ ដុំ   | ក្រោយ៦ខែ |

# មេរៀនទី ៤: អនាម័យ និង វិធានការណ៍ការពារជម្ងឺ

## ១. គោលបំណង

ក្រោយវគ្គបណ្តុះបណ្តាលសិក្ខាកាមនិងបានយល់ដឹងពីៈ

- កិច្ចការជាប្រចាំក្នុងការចិញ្ចឹមមាន់ ដើម្បីជៀសវាងការកើត និងឆ្លងជម្ងឺ
- វិធានការណ៍អនាម័យមុនពេលដាក់មាន់ចិញ្ចឹម
- ការថែទាំមាន់ឆ្លើយតបនឹងអាកាសធាតុប្រែប្រួល

## ២.ការងារជាប្រចាំនៅក្នុងទ្រុងមាន់

- ពិនិត្យរាល់ថ្ងៃ តើស្នូកទឹក ស្នូកចំណី គ្រប់គ្រាន់ដែរឬទេ?
- លាង សំអាតស្នូកទឹក ស្នូកចំណីជាប្រចាំកុំឲ្យធំលក្លិនឬមានផ្សិត
- បោសសំអាតទ្រុងមាន់មួយថ្ងៃ១ដងឬ ២ដងក្នុង១ថ្ងៃ
- ផ្តល់ចំណីឲ្យបានគ្រប់គ្រាន់២ទៅ៣ដង ក្នុងមួយថ្ងៃ
- ដាក់ទឹកនិងចំណីឲ្យបាន២-៣កន្លែងក្នុងទីធ្លា
- ចំណីដុះផ្សិត ផ្អូម មិនត្រូវផ្តល់ឲ្យមាន់ស៊ីទេ ប្រមូលស៊ុតជារៀងរាល់ថ្ងៃ
- ចំពោះមាន់ ឈឺឬងាប់ ត្រូវយកចេញភ្លាម ការពារកុំឲ្យឆ្លងទៅមាន់ក្នុងទ្រុង



ការលាងសំអាតស្នូកចំណី



ការធ្វើអនាម័យ និងផ្តល់ចំណីកូនមាន់



ការដុត ឬកប់សាកសពមាន់ដែលស្លាប់

## ៣.សំបុកពង

មានគ្រប់មេពង ធ្វើសំបុកនៅអាទិត្យទី១៨ មុនពេល ពង១ទៅ២អាទិត្យដើម្បីឲ្យវាដឹងជាបណ្តើរៗ។ សំភារៈធ្វើសំបុកពង គ្មានធូលី អាចស្រូបសំណើមយ៉ាងរហ័ស៖ ចំបើងស្ងួត ស្លឹកសារម៉ាវព្រៃ ស្លឹកទាប ស្លឹកស្ពៅ កំទេចថ្នាំជក់ កំទិចក្រណាត់ កំទិចឈើ ....។



សំបុកពងត្រូវធ្វើឲ្យបានគ្រប់មេមាន់

## ៤.ការអនាម័យកន្លែងចិញ្ចឹម

- ឆ្កែ ឆ្មា មនុស្សមកពី ចំងាយមិនឲ្យចូលក្នុងទ្រុងមាន់
- ដាំស្លឹកគ្រៃ ជុំវិញទ្រុង និងទីធ្លា ព្រោះស្លឹកគ្រៃ មានក្លិនធ្វើឲ្យមូសមិនអាចនៅជិតបាន
- សំអាតព្រៃជុំវិញកន្លែង(ទ្រុង)ចិញ្ចឹម លប់ដីគ្រលុកដក់ទឹកឲ្យបានស្អាតល្អ
- ក្រាលអង្កាមបាតទ្រុង ឬ កំទេចអាចម៍រណារ រក្សាកម្រាលទ្រុងឲ្យស្ងួតជានិច្ច
- កន្លែងមាន់ដេក (ទ្រុង) បោសសំអាតកើបលាមកចេញរាល់ថ្ងៃ





បាចទឹកកំបោរខាងក្រៅ និងក្នុងទ្រុងមាន់មុនពេលបញ្ចូលមាន់

- ការគ្រប់គ្រងកាកសំណល់ លាមកមាន់ថ្មីឲ្យបានល្អ ក្នុងម្លប់ កុំដាក់ហាលថ្ងៃផ្ទាល់ ដាក់ក្នុងម្លប់ដើម្បីកាត់បន្ថយការបំភាយឧស្ម័នមេតាន ទៅក្នុងបរិយាកាសដែលធ្វើឲ្យបម្រែបម្រួលអាកាសធាតុ ។
- សម្លាប់មេរោគ និងបរាសិត (ក្នុងទ្រុង និងទីធ្លាចិញ្ចឹម) រៀងរាល់មុនពេលដាក់មាន់យ៉ាងតិច ១ អាទិត្យ ដោយបាចកំបោរសដើម្បីកុំឲ្យមាន់ឆ្លងមេរោគ
- ឬ ប្រើ ក្នុងសូលុយស្យុង(ទឹកថ្នាំ) វីមីុច-អុីយ៉ូឌីន (Vime-Iodine)ចំណុះ១០សេសេ លាយជាមួយទឹក ១០លីត្របាញ់ក្នុង និងក្រៅទ្រុង។







ទឹកថ្នាំ វីមីុច- អុីយ៉ូឌីន

## ៥. ការថែទាំនៅរដូវក្ដៅ ឬរស្សា និងពេលត្រជាក់ (ខែរងារ)

រដូវទាំងនេះមាន់ស៊ីចំណីថយចុះ ពងថយចុះការធំធាត់យឺតងាយទទួលជម្ងឺ៖

- បន្ថែមសំបកខ្យង គ្រែង ក្ដាម... កិនឲ្យម៉ត់ល្អលាយចំណីឲ្យមាន់ស៊ី
- បន្ថែមវីតាមីនក្នុងទឹក ពេលក្ដៅលាយថ្នាំបញ្ចុះកំដៅ (អាចប្រើថ្នាំបុរាណជាការល្អ)
- មានមាន់១ ឬ២ក្បាលសំកុក ឬឈឺត្រូវថែមថ្នាំអង់ទីប៊ីយ៉ូទីកជាមួយ (ព្យាបាល)។





ស្លឹកស្ដៅ ឬ ម្សៅគ្រាប់ស្ដៅ ឬ ទឹកវល្លពេជ្រត្រាំ ឲ្យមាន់ផឹក

## ៦. វិធានការណ៍ក្នុងការដាក់មាន់ចិញ្ចឹម

- មាន់ទិញ ឬ យកចូលថ្មី រក្សាទុកដោយឡែកដាច់ពីគេ ១៤ ថ្ងៃ ។ បើសិនមានសុខភាពល្អ ទើបដាក់ចូលជាមួយមាន់ចាស់បាន។
- មិនត្រូវទិញមាន់ពីកន្លែងកើតជម្ងឺមកចិញ្ចឹម។

# មេរៀនទី ៥: ជម្ងឺ និង ការចាក់ថ្នាំការពារ

## ១. ជម្ងឺអាសន្នរោគ

- ❖ ឈឺ ខែ មីនា- មិថុនា ឆ្លង តាមការដឹកនាំសត្វ។
- ❖ **រោគសញ្ញា**
  - ហៀរទឹកមាត់ សំបោរ ដង្ហើមដកញាប់ គ្រុនក្តៅកំដៅខ្ពស់
  - សំកុកមិនស៊ីចំណី រាគពណ៌លឿងព្រលៃតលាយសំបោរឈាម
  - មុខ សិរ ណង់ ពណ៌ស្វាយបន្ទាប់មកឡើងខ្មៅជាំ
  - ប្រកាច់ងាប់
- ❖ ព្យាបាលទាំងមាន់ឈឺនិងមាន់មិនឈឺ ប្រើថ្នាំ៖
  - o **អាណាល់ហ្សាំង (ANALGIN-C)**
    - បញ្ចុះកំដៅ បន្ថយការឈឺចាប់
    - ថ្នាំគ្រាប់ ១00ក្រាម លាយចំណី៤0គីឡូក្រាម
    - ប្រើថ្នាំ៣ទៅ៧ថ្ងៃ
  - o **ក្លរ៉ាំតេត្រាហ្សូន(CHLORAMTETRASONE)**
    - រលាកប្រព័ន្ធដង្ហើមរ៉ាំរ៉ៃ
    - ចាក់សាច់ដុំ ចាក់ក្រោមស្បែក បរិ្យ១សេសេ/៥គីឡូទម្ងន់សត្វរស់/ថ្ងៃ
    - ប្រើ៣ទៅ៥ថ្ងៃ
- ❖ **វិធានការការពារជម្ងឺ**
  - សំអាតស្នូកទឹក-ចំណី ទីធ្លាក្នុងក្រៅទ្រុងនិង បាញ់ថ្នាំរំងាប់មេរោគ (ប៊ីយ៉ូឌីន)
  - ចាក់វ៉ាក់សាំងការពារជម្ងឺទៀងទាត់មុនពេលផ្ទុះជម្ងឺ។
    ហាមចោលមាន់ងាប់ពាសវាលពាសកាល។



ជម្ងឺអាសន្នរោគ




ថ្នាំអាណាល់ហ្សាំង-សេ



ការចាក់ថ្នាំព្យាបាល (ចាក់សាច់ដុំ)




ថ្នាំក្លរ៉ាំតេត្រាហ្សូន

- **ការចាក់ថ្នាំការពារ** : វ៉ាក់សាំងអាសន្នរោគមាន់ (ថៃ)
  - ចាក់សាច់ដុំ ១សេសេ/២គីឡូក្រាមមាន់រស់។ សត្វមានភាពស៊ាំ ទល់និងជំងឺ ៦ខែ។ ប្រើសម្រាប់មាន់អាយុ ៣ខែឡើង។

## ២. ជម្ងឺញូខាស ឬ ជម្ងឺដង្កោរ

- មាន់ឈឺ ក្នុងខែកុម្ភៈ ដល់ ឧសភា។
- ឆ្លងតាម ខ្យល់ ទឹកសំបោរ ការកណ្តាស់ លាមកសត្វឈឺ ចំណីអាហារ មនុស្ស សត្វ មធ្យោបាយធ្វើដំណើរ ពងមាន់ឈឺ
- **រោគសញ្ញា**
  - មិនស៊ីចំណីតែផឹកទឹកច្រើន លាមករាគពណ៌ខៀវប្រែទៅជាស មានក្លិនឆ្អាប ហៀរទឹកសំបោរទឹកភ្នែកមាន់ងោកងុយ
  - ក្អកកណ្តាស់ ក្បាលតែហើមប៉ោង
  - រមួលកទៅចំហៀងទៅក្រោយបត់ចុះឡើង(តែវ៉េ)
  - សំយ៉ុងស្លាប កាច់រមួលជើង
  - កំដៅក្នុងខ្លួនឡើងខ្ពស់ កូនមាន់ មាន់ជំទង់ ងាប់ច្រើនជាងមាន់ធំ






- **វិធានការការពារជម្ងឺ**
  - មាន់ឈឺសម្លាប់ កប់ ឬដុតចោល សំអាតស្នូកទឹកស្នូកចំណី ទីធ្លាក្នុងក្រៅទ្រុងនិងបាញ់ថ្នាំរំងាប់មេរោគ
  - **វីមីអ៊ីយូឌីន (សម្លាប់មេរោគគ្រប់ប្រភេទ) ១ ដបចំណុះ ១លីត្រ**
    - សម្លាប់មេរោគនៅទ្រុង សត្វ គ្រឿងដឹកជញ្ជូន ពីឃាតសត្វ ទីផ្សារលក់សត្វ:១៥ មីល្លីលីត្រ/៤លីត្រ បាញ់សម្លាប់មេរោគផ្ទាល់នៃទ្រុង ឬ រោងដែលកំពុងចិញ្ចឹមសត្វ ១៥មីល្លីលីត្រ/៤លីត្រទឹក
    - ចាក់វ៉ាក់សាំងការពារឲ្យបានទៀងទាត់មុនពេលផ្ទុះជម្ងឺ។
- **ការចាក់ថ្នាំការពារ : វ៉ាក់សាំង ញូកាស** $I_2$
  - បន្តក់ភ្នែក លាយទឹក លាយជាមួយចំណី(បាយ)ឬចាក់ ។ បន្តក់ភ្នែក ប្រសិទ្ធិភាព៧០-៨០% ។ ប្រើសម្រាប់មាន់គ្រប់វ័យ (១ថ្ងៃ ទៅពេញវ័យ)។

## ៣. ជម្ងឺអុតបក្សី

សត្វឈឺគ្រប់រដូវ

❖ **រោគសញ្ញា:**

- **ស៊ើរស្បែក** : ដុំពកតូចពណ៌កុលាប ឬពណ៌លឿង ប្រែជាក្រមរ សិរ ខ្ទង់ច្រមុះ ជុំវិញភ្នែក ត្រចៀក ជើង កើតលើភ្នែកធ្វើឲ្យភ្នែកខ្វាក់ កើតលើចំពុះពិបាកស៊ី ផឹក កើតលើច្រមុះពិបាកដកដង្ហើម ។
- **អុតក្នុងមាត់ និងក្នុងបំពង់ក** : រលាកកកឈាម មានចំណុចពណ៌លឿង រាលពកជាដុំ ឬជាបន្ទះច្បាមជាប់នៅក្នុងមាត់។ បន្ទះបិតនោះបិទជាប់បំពង់ក ស្ទះដង្ហើមងាប់។
- **អុតនៅលើភ្នែក និងច្រមុះ** : រលាកភ្នែក ពពឹកភ្នែក គ្របកភ្នែកជាប់គ្នា ច្រមុះរលាកហៀរទឹកពេលទឹកច្រមុះស្ងួតក្រៀមបិទរន្ធច្រមុះ ពិបាកដកដង្ហើម





មាន់កើតជម្ងឺអុត

❖ អនាម័យ ការចាក់ថ្នាំការពារ សំលាប់រុយ ល្បោម ជាភ្នាក់ងារចំលងមេរោគ

❖ **វិធានការការពារជម្ងឺ៖** មាន់ឈឺចាប់ចេញក្រុងទុកដោយឡែកដើម្បីព្យាបាល។ សំអាតស្នូកទឹកស្នូកចំណី។

- បោសសំអាតទីធ្លាក្នុងក្រៅទ្រុងនិងបាញ់ថ្នាំរំងាប់មេរោគ(ប៊ីយ៉ូឌីល)
- ចាក់វ៉ាក់សាំងការពារជម្ងឺឲ្យបានទៀងទាត់មុនពេលផ្ទុះជម្ងឺ

❖ **ការព្យាបាល៖** បេះដំពកចេញ លាបថ្នាំបេតាឌីន (ថ្នាំក្រហមលាយជាមួយប៉េនីស៊ីលីន)និងប្រើបន្ថែម (ច្រកឬចាក់ថ្នាំ)៖

- **អាណាល់ហ្សាំងសេ (ANALGIN-C)**
  - បញ្ចុះកំដៅបានល្អ និងបន្ថយការឈឺចាប់ ពេលមានរបួស
  - ថ្នាំគ្រាប់ ១០០ក្រាម លាយចំណី៤០គីឡូក្រាម ប្រើចំនួន៣ទៅ៧ថ្ងៃ។
- **បេ-កំប្លិច (B-COMPLEX)**
  - ការពារ និងព្យាបាលជម្ងឺកង្វះវីតាមីនក្រុម បេ (B) ។ បំបាត់ស្ត្រេស




ថ្នាំ ទីឡូ ដេសេ

- សត្វចុះខ្សោយអស់កម្លាំង រលាកសាច់ដុំ បាត់ការស្រេកឃ្លាន
- ថ្នាំគ្រាប់៖ ១០០ក្រាម លាយចំណី៥០គីឡូក្រាម

○ **ទីឡូ ដេសេ (TYLO-DC)**
   - ព្យាបាល រលាកសួត ផ្លូវដង្ហើម និងរលាកសន្លាក់ ។ ចាក់សាច់ដុំ ១សេសេ សម្រាប់១០គីឡូសត្វរស់។

❖ **វ៉ាក់សាំងអុតបក្សី**
- វ៉ាក់សាំងកកដុំ លាយទឹក ៥មីល្លីលីត្រ ១ដប សម្រាប់មាន់ ២០០ក្បាល
- ភាពស៊ាំទល់ ទប់ទល់ជំងឺ បាន១ឆ្នាំ
- យកម្ជុលពិសេស ជ្រលក់ជ្រៅក្នុងដបវ៉ាក់សាំង រួចចាក់ធ្លុះទៅក្នុងស្លាបមាន់ (មិនឲ្យប៉ះសាច់ដុំឬសសៃឈាម)។

## ៤. ជម្ងឺផ្តាសាយបក្សី




**មាន់កើតជម្ងឺផ្តាសាយបក្សី**

សត្វឈឺ គ្រប់រដូវ។

❖ ឆ្លងតាមរយៈការប៉ះពាល់ ជាមួយលាមកសត្វសំបោរនិង ការប្រើប្រាស់សម្ភារៈដែលមានជាប់មេរោគ

❖ **រោគសញ្ញាលើមាន់**
- ពិបាកដកដង្ហើម ដង្ហើម ក្រកៗ ខ្ទិន ញ័រក្បាល រមួលក
- ដំណើរវិលវល់ មិនស៊ីចំណី ចុះខ្សោយ និងក្បាលសំយ៉ុងចុះក្រោម
- សិរ ណង់ហើមជាំឈាម ពណ៌ខៀវស្វាយ រាគរូសយ៉ាងខ្លាំង លាមកពណ៌បៃតង បះរោម
- ជាំឈាមនៅនិងជើង និងផ្នែកផ្សេងទៀត ដែលគ្មានរោម
- ការផលិតស៊ុតមានការថយចុះ ស៊ុតមានរូបរាងខុសប្រក្រតី សំបកស៊ុតទន់

❖ **វិធានការការពារជម្ងឺ**
- ធ្វើទ្រុងបែបជីវសុវត្ថិភាព។ បោសសំអាតទ្រុង បាញ់ថ្នាំរំងាប់មេរោគ(វីម៉ី-អ៊ីយ៉ូឌីន) បាញ់សម្លាប់មេរោគ ផ្ទាល់នៃទ្រុង ឬ រោងកំពុងចិញ្ចឹមសត្វ: ១៥ មីល្លីលីត្រ/៤លីត្រទឹក
- ទិញបក្សីមកចិញ្ចឹមត្រូវក្រុងទុក១៤ថ្ងៃ (ដើម្បីតាមដានជម្ងឺ)
- អ្នកចិញ្ចឹមពេលចេញ-ចូល ទ្រុងត្រូវសំអាតជើង ដៃ
- មានមាន់ឈឺក្នុងហ្វូង ត្រូវសម្លាប់ចោលទាំងឈឺទាំងមាន់ជា។

ថ្នាំសម្លាប់មេរោគគ្រប់ប្រភេទ




**ថ្នាំរំងាប់មេរោគ(វីម៉ី-អ៊ីយ៉ូឌីន)**

# មេរៀនទី ៦: ការបញ្ចូលរបៀបថ្មី លើគោលគំនិត អាជីវកម្មកសិកម្មខ្នាតតូច ផ្នែកការចិញ្ចឹមមាន់

## តើត្រូវធ្វើដូចម្តេចខ្លះដើម្បីចាប់ផ្តើមចិញ្ចឹមមាន់?

មនុស្សភាគច្រើនបរិភោគ សាច់មាន់ជាអាហារពេលព្រឹក បាយថ្ងៃត្រង់ និងប្រើប្រាស់ក្នុងព្រឹត្តិការណ៍ ផ្សេងៗះបុណ្យទាន អាពាហ៍ពិពាហ៍ ចូលឆ្នាំចិន ចូលឆ្នាំខ្មែរ បុណ្យប្រពៃណីផ្សេងៗ ។ ទាំងអស់ នេះហើយដែលត្រូវការមាន់ជាចាំបាច់។

### ១. ចំណេះដឹងអំពីមាន់ រាប់បញ្ចូលទាំងះ

- យកចិត្តទុកដាក់វិធីសាស្រ្តអនាម័យ និងចំណីមាន់?
- វដ្តជីវិតរបស់មាន់ និងការថែរក្សា?
- យកចិត្តទុកដាក់ចិញ្ចឹមបន្តិចបន្តួចសិនមុនចាប់ផ្តើមជាកសិដ្ឋានធំ

### ២. សម្រេចចិត្តថា ពូជមាន់ណាដែលអ្នកចង់ចិញ្ចឹម និងបានតម្លៃថ្លៃនៅលើទីផ្សារ

- គោលបំណងដែលអ្នកចង់បានសម្រាប់កសិដ្ឋានរបស់អ្នក ?
- រកពូជដែលត្រូវតាមគោលបំណងអ្នក ពូជមាន់ជើងខ្មៅ ឬជើងលឿង ឬ ជើងស
- រកទីកន្លែងសម្រាប់សាងសង់ទ្រុង

### ៣. អ្នកផ្គត់ផ្គង់កូនមាន់

- យកកូនមាន់ពីម្ចាស់កសិដ្ឋានដែលស្គាល់ (ប្រភព មិនមានជម្ងឺ)ដឹងច្បាស់ថាបក្សីទាំងនេះពិតជាមានសុខភាពល្អមែន

### ៤. ផែនការថវិកា សម្រាប់ប្រតិបត្តិការកសិកដ្ឋានរបស់អ្នក

- តម្រូវការថវិកាដំណើរការកសិដ្ឋានចិញ្ចឹមមាន់
- ចំណាយប្រចាំសប្តាហ៍ ចំណី ទឹក កំដៅសម្រាប់កូនមាន់
- លទ្ធភាពថវិកា មានផ្ទាល់ខ្លួន ខ្ចះខ្ចីពីសាច់ញាត្តិ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬសហគមន៍ (តាមទំហំការចិញ្ចឹម)

### ៥. ទីកន្លែងសម្រាប់កសិដ្ឋានចិញ្ចឹមមាន់

- ផ្ទៃដីសម្រាប់សាងសង់ទ្រុង(ផ្ទៃដីតូច ឬធំ)

## ៦. ការយល់ដឹងពីការគាំទ្រ ការចិញ្ចឹមមាន់របស់អ្នក

- ឈ្មួញផ្គត់ផ្គង់ចំណី ឬចំណីអាចរកបានក្នុងមូលដ្ឋាន
- ពិភាក្សាជាមួយ ភ្នាក់ងារផ្សព្វផ្សាយ ឬភ្នាក់ងារសុខភាពសត្វភូមិលើសុខភាពមាន់សត្វភូមិ ដែលនៅជិតអ្នកបំផុត ក្នុងការពិភាក្សាពី សុខភាពមាន់ ប្រភេទចំណី ការប្រើប្រាស់ថ្នាំចាក់ការពារ ថ្នាំព្យាបាល និងការផ្តល់វីតាមីនបន្ថែម
- កត្តាមានឥទ្ធិពលលើការផ្គត់ផ្គង់
- ប្រតិទិន្ននៃនៃការចិញ្ចឹមមាន់ តម្រូវការទីផ្សារ និងតម្លៃ

## ៧. ដំណើរការកែច្នៃ ចំណីសត្វ និងប្រភពធនធានដែលមាននៅមូលដ្ឋាន

- ស្វែងយល់ធនធានចំណីមាននៅក្នុងកសិដ្ឋាន ឬអាចរកបានច្រើននៅមូលដ្ឋាន និងតម្លៃថោក

## ៨. តម្លៃ -ជំហ៊ានកែច្នៃ

- ការប្រមូលផល ការទុកដាក់ ការកែច្នៃ និងគុណភាព នៃផលិតផល

## ៩. តម្រូវការសម្ភារៈ និងបរិក្ខាសម្រាប់កសិដ្ឋានចិញ្ចឹមមាន់

- ម៉ាស៊ីនកិន និងផ្សំចំណី ទូរភ្ញាស់ស៊ុតមាន់
- សម្ភារៈផ្សេងៗ សម្រាប់ប្រមូលកាលសំណល់ការចិញ្ចឹមមាន់
- ដង្ហាល់បូមខ្យល់ចេញ (បើចិញ្ចឹមជាខ្នាតធំ)
- ការផ្តល់ចំណីបន្ថែម (សារធាតុរ៉ែ ប្រេមិច) និងឧបករណ៍ដាក់ទឹក ក្រដាសកាតុងដាក់ពងមាន់
- ឧបករណ៍ ត្រួតពិនិត្យជម្ងឺ និងសត្វល្អិត

## ១០. ការភ្ជាប់បណ្តាញ និងភាពជាដៃគូរ

- ក្នុងខេត្ត ភោជនីយដ្ឋាន សណ្ឋាគារ ឈ្មួញក្នុងស្រុក អ្នកកែច្នៃសាច់
- ភ្ជាប់បណ្តាញជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក រាជរដ្ឋាភិបាល និងផ្នែកឯកជន សម្រាប់ទីផ្សារឲ្យបានច្រើនកន្លែង ឬ នាំចេញ

## ១១. លំហូរនៃពត៌មានទីផ្សារ (ប្រព័ន្ធទីផ្សារវៃឆ្លាត ឬ សេវាកម្មពត៌មានទីផ្សារ)

ប្រើប្រាស់ប្រព័ន្ធពត៌មានដែលបានចងក្រង ធ្វើការវិភាគ និងការផ្សព្វផ្សាយអំពីតម្លៃទាក់ទងនឹង កសិករខ្នាតតូចដែលចិញ្ចឹមសត្វ ឈ្មួញ អ្នកកែឆ្នៃ អ្នកដែលមានទំនាក់ទំនងផ្សេងទៀតក្នុងការប្រើផលិផលកសិកម្ម។

### ប្រតិទិនរដូវកាល នៃការចិញ្ចឹមមាន់ តម្រូវការទីផ្សារ និងតម្លៃ

| ល.រ | សកម្មភាព | ប្រតិទិន | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ១ | **ការងារយេនឌ័រ** | | | | | | | | | | | | |
| | បុរស ស្ត្រី ស្ទូង | | | | | | | | | | | | |
| | បុរស ស្ត្រី ច្រូតកាត់ | | | | | | | | | | | | |
| | បុរស ស្ត្រី ចិញ្ចឹមមាន់ (ខែចិញ្ចឹមល្អ) | | | | | | | | | | | | |
| ២ | **ចាក់ថ្នាំការពារជម្ងឺ** | | | | | | | | | | | | |
| | ញូកាស | | | | | | | | | | | | |
| | អាសន្នរោគ | | | | | | | | | | | | |
| | អុតបក្សី ចាក់ពេលកូនទើបកើត | | | | | | | | | | | | |
| ៣ | **មាន់កើតជំងឺច្រើន** | | | | | | | | | | | | |
| | អាសន្នរោគ | | | | | | | | | | | | |
| | ញូកាស | | | | | | | | | | | | |
| ៤ | **តម្រូវការទីផ្សារ និងផលិតផល** | | | | | | | | | | | | |
| | តម្លៃមាន់ ចុះថោកលក់មិនសូវដាច់ | | | | | | | | | | | | |
| | មាន់លក់បានថ្លៃ | | | | | | | | | | | | |

# តារាងផែនការអាជីវកម្ម ការចិញ្ចឹមមាន់

កាលបរិច្ឆទេសចាប់ផ្តើមអាជីវកម្ម៖.......................................................

## ១.ចំណាយថ្លៃវត្ថុធាតុដើម

| រាយមុខទំនិញ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| ពូជមាន់  | ក្បាល | | | |
| ចំណី    | គក្រ | | | |
| វ៉ាក់សាំង និងថ្នាំព្យាបាល   | សរុប | | | |
| **សរុបចំណាយថ្លៃវត្ថុធាតុដើម** | | | | |

## ២.ចំណាយថ្លៃឧបករណ៍/សម្ភារះ

| រាយមុខឧបករណ៍/សម្ភារះ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| ឈើធ្វើទ្រុង  | សរុប | | | |
| ស្លឹកកណ្តប ដែកគោល   | សរុប | | | |
| ស្នូកទឹក ស្នូកចំណី | | | | |
| ធុងទឹកសុទ្ធ និងក្បាលបឺត | សរុប | | | |
| **សរុបចំណាយថ្លៃឧបករណ៍/សម្ភារះ** | | | | |

**សរុបចំណាយទាំងអស់** ................................. + ................................. = .................................

## តារាង ការវិភាគចំណូលចំណាយ ក្នុងការចិញ្ចឹមមាន់

| រាយមុខទំនិញ | ឯកតា | ចំនួន | តម្លៃ១ឯកតា(រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|
| **១.ចំណាយផលិតកម្ម** | | | | |
| **ក.ថ្លៃវត្ថុធាតុដើម** | | | | |
| ពូជមាន់  | ក្បាល | | | |
| ចំណី    | គក្រ | | | |
| សំបកខ្យង  ស្លឹករុក្ខជាតិ  | គក្រ | | | |
| វ៉ាក់សាំង និងថ្នាំព្យាបាល   | សរុប | | | |
| **សរុបរងថ្លៃវត្ថុធាតុដើម** | | | | |
| **ខ.ថ្លៃឧបករណ៍/សំភារៈ** | | | | |
| ទ្រុងមាន់ (រំលោះ ៣ឆ្នាំ)  | ទ្រុង | | | |
| ស្នូកទឹក ស្នូកចំណី   | ចំនួន | | | |
| **សរុបរងថ្លៃឧបករណ៍/សំភារៈ** | | | | |
| **គ.ថ្លៃពលកម្ម** | | | | |
| ថ្លៃពលកម្មផ្តល់ចំណី និងថែទាំមាន់ | នាក់/ថ | | | |
| **សរុបរងថ្លៃពលកម្ម** | | | | |
| **សរុបចំណាយផលិតកម្ម (ថ្លៃវត្ថុធាតុដើម +សំភារៈ + ពលកម្ម)** | | | | |

| | | | | |
|---|---|---|---|---|
| ២.ចំណូលៈផលិតផលដែលសម្រេចបាន) | | | | |
| មាន់ពេញវ័យ  | ក្បាល | | | |
| មេមាន់  | ក្បាល | | | |
| កូនមាន់  | ក្បាល | | | |
| ពងមាន់  | ក្បាល | | | |
| អាចមន៍មាន់  | បាវ | | | |
| សរុបរងចំណូលផលិតកម្ម | | | | |
| ៣.ការប្រើប្រាស់ក្នុងគ្រួសារ | | | | |
| មាន់  | ក្បាល | | | |
| ពងមាន់  | ចំនួន | | | |
| សរុបរងការប្រើប្រាស់ក្នុងគ្រួសារ | | | | |
| ៤.បរិមាណ មាន់ ទុកពូជ | | | | |
| មេមាន់  | ក្បាល | | | |
| កូនមាន់ និងមាន់ពេញវ័យ   | ក្បាល | | | |
| សរុបរងបរិមាណទុកពូជ | | | | |
| សរុបចំណេញ = ចំណូលផលិតកម្ម -ចំណាយផលិតកម្ម | | | | |
| សរុបប្រាក់ចំណេញសុទ្ធ= ចំណេញ -(ប្រើប្រាស់ក្នុងគ្រួសារ + ទុកពូជ) | | | | |

បញ្ហាកើតមានក្នុងការចិញ្ចឹមមាន់.............................................................................................................................

# ឯកសារយោង

១.សៀវភៅបណ្តុះបណ្តាលបច្ចេកទេសការចិញ្ចឹមមាន់តាមសហគមន៍ គម្រោងឱកាសអាជីវកម្មសម្រាប់ស្ត្រីវ័យក្មេង (YWIB) ឆ្នាំ ២០១៣ អង្គការយេរកម្ពុជាខេត្តកោះកុង

២.ឯកសារបណ្តុះបណ្តាលស្តីពី បច្ចេកទេសភ្ញាស់ស៊ុតមាន់ដោយប្រើ ទូភ្ញាស់ ការក្រៀវមាន់និងក្រៀវជ្រូក ការចិញ្ចឹមកូនជ្រូកបៅដោះ ការចិញ្ចឹមជ្រូកបា កត្តាជួបប្រទះផ្សេងៗក្នុងការចិញ្ចឹមជ្រូក មាន់ និងវិធីសាស្ត្រទប់ស្កាត់ជំងឺឆ្លងក្នុងតំបន់ចំពោះជ្រូក មាន់ភាពជាអ្នកដឹកនាំផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រីជនបទ (LEL) អង្គការយេរកម្ពុជា ខេត្តកោះកុង ឆ្នាំ ២០១៤

៣.សៀវភៅកសិករ កម្រងបច្ចេកទេសកសិកម្មល្អៗ ធន់នឹងអាកាសធាតុប្រែប្រួលខែវិច្ឆិកា ឆ្នាំ ២០១៥។ អង្គការ Action Aid, PIN, Save the Children, Oxfam និងនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

Version: 1

កាលបរិច្ឆេទបោះពុម្ពៈ ខែ វិច្ឆិកា ឆ្នាំ ២០១៦

ចំនួនៈ  ១000ក្បាល